# សម្រាប់ការចេញផ្សាយបន្ទាន់

***** រូបថតមាននៅ *****

www.hrwnews.org/press/cambodia_malaysiadomesticworkers.zip

## កម្ពុជា / ម៉ាឡេស៊ី ៖ ពលករធ្វើការតាមផ្ទះប្រឈមនឹងការរំលោភបំពាន

*សូមពង្រីកកិច្ចការពារខាងការងារដល់ស្ត្រីនិងកុមារីចំណាកស្រុកនៅក្នុងប្រទេសនិងក្រៅប្រទេស*

(ភ្នំពេញ, ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១១) - អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានចុះផ្សាយក្នុងរបាយការណ៍ថ្ងៃនេះថា ការខកខានរបស់រដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលម៉ាឡេស៊ី ដើម្បីដាក់បទប្បញ្ញត្តិគ្រប់គ្រងលើអ្នកជ្រើសរើសនិងនិយោជក ធ្វើឲ្យពលករចំណាកស្រុកធ្វើការតាមផ្ទះជាតិកម្ពុជា ទទួលរងនូវការរំលោភដ៏រីករាលដាល។ ស្ត្រីនិងកុមារីកម្ពុជាជាច្រើនពាន់នាក់ ដែលធ្វើចំណាកស្រុកទៅកាន់ប្រទេសម៉ាឡេស៊ី ទទួលបាននូវការការពារបន្តិចបន្តួច ពីការបង្ខាំងខ្លួននៅក្នុងមណ្ឌល ពីបន្ទុកបំណុលដ៏ធ្ងន់ធ្ងរ និងពីល័ក្ខខ័ណ្ឌការងារមានលក្ខណៈកេងប្រវ័ញ្ច។

របាយការណ៍ដែលមាន១០៥ទំព័រស្តីពី "ពួកគេបោកប្រាស់យើងគ្រប់ជំហាន៖ ការរំលោភលើអ្នកធ្វើការតាមផ្ទះជាតិកម្ពុជា ដែលធ្វើចំណាកស្រុកទៅកាន់ប្រទេសម៉ាឡេស៊ី" ជារបាយការណ៍ដែលចងក្រងបទពិសោធន៍របស់ពលករធ្វើការតាមផ្ទះជាតិកម្ពុជា ក្នុងអំឡុងពេលជ្រើសរើស អំឡុងពេលធ្វើការនៅក្រៅប្រទេស និងពេលវិលត្រឡប់មកកាន់មាតុភូមិរបស់ពួកគេវិញ។ របាយការណ៍នេះធ្វើឡើងផ្អែកលើការសម្ភាសន៍ចំនួន៨០លើក ជាមួយពលករចំណាកស្រុកធ្វើការតាមផ្ទះ គ្រួសាររបស់ពួកគេ មន្ត្រីរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងទីភ្នាក់ងារជ្រើសរើសពលករ។ របាយការណ៍នេះគូសបង្ហាញពីឧបសគ្គមួយចំនួនដែលធ្វើឲ្យស្ត្រី និងកុមារីដែលទទួលរងការធ្វើបាប មិនទទួលបានយុត្តិធម៌ និងការដោះស្រាយ ក្នុងប្រទេសកម្ពុជានិងប្រទេសម៉ាឡេស៊ី។

យូណា ពូយ៉ាល់ ជាអ្នកស្រាវជ្រាវអំពីសិទ្ធិស្ត្រីនៅឯអង្គការឃ្លាំមើលសិទ្ធិមនុស្ស បានមានប្រសាសន៍ថា "កម្ពុជាបានយកចិត្តទុកដាក់ក្នុងការជំរុញឲ្យមានការធ្វើចំណាកស្រុកពលករ ប៉ុន្តែប្រទេសនេះបានខកខានផ្តល់កិច្ចការពារជាមូលដ្ឋានដល់ស្ត្រីនិងកុមារីចំណាកស្រុក។ រដ្ឋាភិបាលគួរតែបញ្ឈប់ការប្រគល់ការទទួលខុសត្រូវគ្រប់យ៉ាងទៅឲ្យទីភ្នាក់ងារជ្រើសរើសពលករដែលមិនស្មោះត្រង់ និងត្រូវតែបោសសម្អាតឲ្យអស់នូវអំពើកេងប្រវ័ញ្ចនិងអំពើរំលោភបំពាន។"

ចាប់តាំងពីឆ្នាំ២០០៨មក ស្ត្រីនិងកុមារីកម្ពុជាចំនួនសែសិបទៅហាសិបពាន់នាក់ បានធ្វើចំណាកស្រុកទៅកាន់ប្រទេសម៉ាឡេស៊ី ជាអ្នកធ្វើការតាមផ្ទះ។ ភ្នាក់ងារជ្រើសរើសពលករមួយចំនួននៅក្នុងប្រទេសកម្ពុជា បានក្លែងប្រឌិតឯកសារអត្តសញ្ញាណក្លែងក្លាយ ដើម្បីជ្រើសរើសកុមារ និងផ្តល់គ្រឿងទាក់ទាញទឹកចិត្តជាប្រាក់កាសនិងជាអាហារ ដែលនាំឲ្យពលករចំណាកស្រុក និងគ្រួសាររបស់ពួកគេជាប់បំណុលយ៉ាងធ្ងន់ធ្ងរ ធ្វើឲ្យពួកគេយល់ខុសអំពីការទទួលខុសត្រូវចំពោះការងាររបស់ពួកគេនៅក្នុងប្រទេសម៉ាឡេស៊ី និងយកថ្លៃឈ្នួលជ្រើសរើសច្រើនហួសប្រមាណ។

ពលករធ្វើការតាមផ្ទះបានប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សថា ភ្នាក់ងារបានបង្ខំបង្ខាំងអ្នកដែលបានជ្រើសរើសរយៈពេលបីខែ ឬក៏យូរជាងនេះនៅក្នុងមណ្ឌលហ្វឹកហ្វឺនដោយមិនមានអាហារ ទឹក និងការថែទាំផ្នែកពេទ្យឲ្យបានគ្រប់គ្រាន់ឡើយ។ ភ្នាក់ងារជ្រើសរើសពលករមួយចំនួន បង្ខំស្ត្រីនិងកុមារឲ្យធ្វើចំណាកស្រុក ទោះជាពួកគេលែងមានបំណងទៅធ្វើការនៅក្រៅប្រទេសតទៅទៀតក៏ដោយចុះ។ អ្នកធ្វើការដែលភៀសខ្លួនពីមណ្ឌលហ្វឹកហ្វឺន ប្រឈមមុខនឹងការសងសឹកចំពោះការរត់គេចខ្លួន ឬចំពោះការខកខានសងបំណុល ដែលពាក់ព័ន្ធនឹងដំណើរការជ្រើសរើសពលករ។

ប្តីរបស់អ្នកធ្វើការតាមផ្ទះមួយរូប ដែលបានបានភៀសខ្លួនចេញពីមណ្ឌលហ្វឹកហ្វឺន បានប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សថា ៖

> តំណាងពីក្រុមហ៊ុនបាននិយាយថា ប្រសិនបើប្រពន្ធរបស់ខ្ញុំមិនវិលត្រឡប់មកវិញទេ គាត់នឹងដាក់លក់ឡាយឡុងផ្ទះនិងដីនេះ។ ប្រសិនបើការលក់ឡាយឡុងមិនគ្រប់គ្រាន់ទេនោះ ពួកគេនឹងចាប់ខ្ញុំដាក់គុក។

អង្គការឃ្លាំមើលសិទ្ធិមនុស្សបានរកឃើញថា នៅគ្រប់ពេលទាំងអស់ កិច្ចសហការរបស់រដ្ឋាភិបាលកម្ពុជាជាមួយទីភ្នាក់ងារជ្រើសរើសពលករឯកជន បានធ្វើឲ្យពលករមិនអាចស្វែងរកការដោះស្រាយប្រកបដោយប្រសិទ្ធិភាពបានឡើយ។ ពលករធ្វើការតាមផ្ទះមួយរូបបានមានប្រសាសន៍ថា ស្ត្រីពីររូបបានប៉ុនប៉ងធ្វើអត្តឃាតនៅក្នុងមណ្ឌលហ្វឹកហ្វឺនក្នុងប្រទេសកម្ពុជា បន្ទាប់ពីទីភ្នាក់ងារបានច្រានចោលការស្នើសុំរបស់ពួកគេត្រឡប់ទៅផ្ទះវិញ។

ក្រោយមក ភ្នាក់ងារបានរៀបចំការប្រជុំជាមួយអ្នកដែលបានជ្រើសរើសទាំងអស់។ នគរបាលពីររូប ក៏មានវត្តមាននៅទីនោះដែរ។

ពលករមួយរូបបាននិយាយថា "មន្ត្រីនគរបាលបានប្រាប់យើងថា ប្រសិនបើយើង [មានបំណង] ធ្វើអត្តឃាត នោះពួកគេនឹងដាក់គុកពួកយើង។ ពួកគេបាននិយាយផងដែរថា ពួកយើងមិនគួរព្យាយាមរត់គេចខ្លួននោះទេ។ ទោះជាយើងរត់គេចខ្លួនក៏ដោយ ក៏ប៉ូលីសនឹងរក [ពួកយើង] ហើយយើងនៅតែត្រូវបញ្ជូនទៅកាន់ប្រទេសម៉ាឡេស៊ីដដែល។"

ក្នុងការកាត់ទោសប្រកបដោយជោគជ័យជាលើកដំបូងលើទីភ្នាក់ងារជ្រើសរើសមួយនោះ តុលាការកម្ពុជាក្នុងខែកញ្ញា ២០១១ បានកាត់ទោសអ្នកគ្រប់គ្រងម្នាក់របស់ទីភ្នាក់ងារជ្រើសរើសពលករឈ្មោះ វីស៊ីមែនផាវឺ ឲ្យជាប់គុករយៈពេល ១៣ ខែចំពោះការឃុំឃាំងពលករជាកុមារ ដោយខុសច្បាប់។ ប៉ុន្តែយ៉ាងណាក៏ដោយ រដ្ឋាភិបាលបានខកខានក្នុងការនាំយកភ្នាក់ងារជ្រើសរើសពលករដទៃទៀត ដែលពាក់ព័ន្ធនឹងអំពើរំលោភស្រដៀងគ្នានេះមកកាត់ទោស ហើយរដ្ឋាភិបាលក៏មិនបានដកហូតអាជ្ញាប័ណ្ណពីទីភ្នាក់ងារណាមួយក៏ទេដែរ។

ពូយ៉ាល់បានមានប្រសាសន៍ថា "ទោះជាមានការកាត់ទោសភ្នាក់ងារមួយរូបដែលប្រព្រឹត្តិរំលោភបំពាននោះហើយក៏ដោយ ក៏វានៅតែមានការលើកលែងមួយជាដដែល។ រដ្ឋាភិបាលកម្ពុជា ត្រូវតែបញ្ចប់ការកេងប្រវ័ញ្ចជាប្រព័ន្ធលើពលករធ្វើការតាមផ្ទះ ដោយធានាថាភ្នាក់ងារទាំងអស់នឹងដាក់ឲ្យទទួលខុសត្រូវចំពោះអំពើរបស់ពួកគេ។"

កាលនៅក្នុងប្រទេសម៉ាឡេស៊ី ស្ត្រីនិងកុមារីកម្ពុជា ជាញឹកញយត្រូវតែប្រគល់លិខិតឆ្លងដែនរបស់ពួកគេឲ្យទៅភ្នាក់ងាររបស់ពួកគេ ឬឲ្យទៅនិយោជករបស់ពួកគេ ដែលប្រការនេះធ្វើឲ្យពួកគេពិបាកចាកចេញ ប្រសិនបើពួកគេត្រូវបានគេធ្វើបាន។ ពលករជាច្រើននាក់ធ្វើការពី១៤ម៉ោង ទៅ២១ម៉ោងក្នុងមួយថ្ងៃ ដោយគ្មានពេលឈប់សម្រាក ឬថ្ងៃឈប់សម្រាកនោះទេ។ ហើយពលករជាច្រើននាក់ត្រូវបានគេបង្ខាំងដោយបង្ខំ ឲ្យនៅតែកន្លែងធ្វើការ មិនបានទទួលអាហារគ្រប់គ្រាន់ និងទទួលរងនូវការរំលោភលើរាងកាយ និងរំលោភដោយពាក្យសម្តី។ អ្នកខ្លះត្រូវនិយោជករំលោភខាងផ្លូវភេទ។ ពលករដែលអង្គការឃ្លាំមើលសិទ្ធិមនុស្ស បានសម្ភាសន៍ គ្មានពលករណាម្នាក់និយាយថាពួកគេបានទទួលប្រាក់ខែពេញលេញនោះទេ។

អង្គការឃ្លាំមើលសិទ្ធិមនុស្សបាននិយាយថា ច្បាប់ការងាររបស់ប្រទេសម៉ាឡេស៊ី ផាត់ចោលពលករចំណាកស្រុកធ្វើការតាមផ្ទះពីកិច្ចការពារសំខាន់ៗ ដូចជាថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ សម្រាកប្រចាំឆ្នាំ និងការកម្រិតម៉ោងធ្វើការងារ។ ច្បាប់អន្តោប្រវេសន្ត៍ ចងភ្ជាប់ការស្នាក់នៅរបស់ពលករធ្វើការតាម

ផ្ទះជាមួយនឹងនិយោជក ដែលការធ្វើបែបនេះ នាំឲ្យនិយោជក អាចបញ្ចប់កិច្ចសន្យារបស់ពលករធ្វើការតាមផ្ទះតាមបំណងខ្លួន និងមិនអនុញ្ញាតឲ្យពួកគេផ្ទេរការងារ។ គោលនយោបាយទាំងនេះ ដាក់កំហិតដល់លទ្ធភាពរបស់ពលករធ្វើការតាមផ្ទះ ដោយមិនឲ្យពួកគេអាចស្វែងរកការកែប្រែ និងផ្លាស់ប្តូរនិយោជក ក្នុងករណីជួបប្រទះការរំលោភបំពាន។

អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានចងក្រងករណីជាច្រើនដែលនៅក្នុងនោះមាន ការបោកបញ្ឆោត និងការដាក់ឲ្យជាប់បំណុល ក្នុងអំឡុងពេលជ្រើសរើស ការបង្ខាំងដោយបង្ខំ ការមិនផ្តល់ប្រាក់បៀវត្សការគំរាមកំហែងសងសឹកចំពោះការរត់គេចខ្លួន ឬការខកខានសងបំណុលដែលនាំទៅរកការងារបង្ខិតបង្ខំ រួមទាំងការជួញដូរ និងការធ្វើជាទាសករសងបំណុល។ ពលករដែលរងការរំលោភ ជាញឹកញយត្រូវគេបញ្ជូនត្រឡប់ទៅកាន់ភ្នាក់ងារនៅមូលដ្ឋានរបស់ក្រុមហ៊ុនជ្រើសរើសពលកររបស់ពួកគេ ពីព្រោះវាជាទីកន្លែងទាក់ទងតែមួយគត់ ដែលពលករមានក្នុងប្រទេសម៉ាឡេស៊ី ក៏ប៉ុន្តែពលករច្រើននាក់ប្រឈមការបំភិតបំភ័យ និងការបញ្ជូនត្រឡប់ទៅកាន់និយោជកដែលប្រព្រឹត្តរំលោភដដែលជាដែល។ ស្ថានទូតកម្ពុជានៅកូឡាឡាំពួរ ដែលជារាជធានីប្រទេសម៉ាឡេស៊ី បានបញ្ជូនពលករ មានជាអាទិ៍ពលករដែលទទួលរងការរំលោភខាងផ្លូវភេទ និងផ្លូវកាយ ឲ្យវិលត្រឡប់មកកាន់ទីភ្នាក់ងារជ្រើសរើសពលកររបស់ពួកគេ ឬនិយោជករបស់ពួកគេ។

អង្គការឃ្លាំមើលសិទ្ធិមនុស្សនិយាយថា រដ្ឋាភិបាលកម្ពុជាត្រូវបង្កើតច្បាប់ទូលំទូលាយមួយស្តីពីចំណាកស្រុក ត្រូវពង្រឹងការឃ្លាំមើលទីភ្នាក់ងារជ្រើសរើសពលករ និងដាក់ទោសជាចាំបាច់ ខណៈពេលដែលមានការរំលោភកើតឡើង។ រដ្ឋាភិបាលម៉ាឡេស៊ី ត្រូវកែប្រែច្បាប់ស្តីពីការងារ និងការធានារបស់ខ្លួនដើម្បីពង្រឹងកិច្ចការពារដល់ពលករធ្វើការតាមផ្ទះ។ ប្រទេសទាំងពីរគួរបង្កើនសេវាកម្មគាំទ្រសម្រាប់ពលករដែលទទួលរងការរំលោភបំពាន រួមមានជំនួយផ្នែកច្បាប់ និងសេវាចិត្តសាស្ត្រសង្គម។

អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានជំរុញផងដែរឲ្យប្រទេសកម្ពុជា និងប្រទេសម៉ាឡេស៊ី ផ្តល់សច្ចាប័នលើអនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិស្តីពីការងារតាមផ្ទះ។ សន្ធិសញ្ញាតម្រូវឲ្យរដ្ឋាភិបាលធានាឲ្យមានល័ក្ខខណ្ឌការងារសមស្រប កំណត់អាយុអប្បបរមា សម្រាប់ពលករធ្វើការងារតាមផ្ទះ និងការពារពលករធ្វើការតាមផ្ទះពីអំពើហិង្សា និងការអនុវត្តន៍ការជ្រើសរើសបែបកេងប្រវ័ញ្ច។

ពូយ៉ាល់បានមានប្រសាសន៍ថា "ខណៈពេលដែលស្ថានទូតកម្ពុជាក្នុងប្រទេសម៉ាឡេស៊ី បញ្ជូនពលករដែលទទួលរងការរំលោភ ត្រឡប់ទៅកាន់ទីភ្នាក់ងារជ្រើសរើសពលកររបស់ពួកគេវិញ វាកំពុងតែធ្វើឲ្យ

ស្ត្រីដែលបានទទួលរងការឈឺចាប់យ៉ាងអាក្រក់ទៅហើយនោះ កាន់តែស្ថិតនៅក្នុងគ្រោះថ្នាក់នៃអំពើហិង្សាជាបន្តទៀត។ ប្រទេសកម្ពុជានិងម៉ាឡេស៊ី ត្រូវផ្តល់សច្ចាប័នលើអនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិស្តីពីការងារតាមផ្ទះ ក៏ប៉ុន្តែប្រទេសទាំងពីរនេះ គួរតែចាប់ផ្តើមអនុវត្តបទប្បញ្ញត្តិនានារបស់អនុសញ្ញានេះ ថ្វីបើធ្វើមុនការផ្តល់សច្ចាប័នក៏ដោយ ដែលវាជាការបំពេញនូវកិច្ចការពារសិទ្ធិរបស់ពលករធ្វើការតាមផ្ទះ។"

**"ពួកគេបោកប្រាស់យើងគ្រប់ជំហាន ៖ ការរំលោភលើអ្នកធ្វើការតាមផ្ទះជាតិកម្ពុជា ដែលធ្វើចំណាកស្រុកទៅកាន់ប្រទេសម៉ាឡេស៊ី" មាននៅ** http://hrw.org/reports/2011/11/01/they-deceived-us-every-step-0

**របាយការណ៍បន្ថែមរបស់អង្គការឃ្លាំមើលសិទ្ធិមនុស្សស្តីពីពលករចំណាកស្រុកធ្វើការតាមផ្ទះ សូមមើល ៖**

- "កម្ពុជា ៖ កែសម្រួលកែប្រែឡើងវិញនូវវិធានការការពារពលករចំណាកស្រុកធ្វើការតាមផ្ទះ" (ខែតុលា ឆ្នាំ២០១១) ៖ http://www.hrw.org/news/2011/10/14/cambodia-overhaul-protections-migrant-domestic-workers
- "កម្ពុជា ៖ ការផ្លាស់ប្តូរបន្តិចបន្តួចលើបទប្បញ្ញត្តិថ្មីស្តីពីពលករធ្វើការតាមផ្ទះ" (ខែសីហា ឆ្នាំ២០១១) http://www.hrw.org/news/2011/08/30/cambodia-new-regulation-short-changes-domestic-workers
- អានីស ហ៊ីដាយ៉ាស ដែលបានប្រគល់កិត្តិយសដោយអង្គការឃ្លាំមើលសិទ្ធិមនុស្ស ក្នុងឆ្នាំ២០១១ នូវរង្វាន់របស់អាលីសុន ដេ ហ្វក ចំពោះសកម្មជនភាពវិសាមញ្ញ ៖ http://www.hrw.org/node/100827
- "អង្គការពលកម្មអន្តរជាតិ ៖ សន្ធិសញ្ញាដ៏សំខាន់ថ្មីមួយដើម្បីការពារពលករធ្វើការតាមផ្ទះ" (ខែមិថុនា ឆ្នាំ២០១១) http://www.hrw.org/news/2011/06/16/ilo-new-landmark-treaty-protect-domestic-workers
- "ឥណ្ឌូនេស៊ី/ម៉ាឡេស៊ី ៖ ការផ្លាស់ប្តូរបន្តិចបន្តួចលើកតិកាសញ្ញាថ្មីស្តីពីពលករធ្វើការតាមផ្ទះ" (ខែឧសភា ឆ្នាំ២០១១)៖ http://www.hrw.org/news/2011/05/31/indonesiamalaysia-new-pact-shortchanges-domestic-workers

**សម្រាប់របាយការណ៍បន្ថែមពីអង្គការឃ្លាំមើលសិទ្ធិមនុស្សស្តីពីសិទ្ធិស្ត្រី សូមមើល ៖**
http://www.hrw.org/category/topic/women

**សម្រាប់របាយការណ៍បន្ថែមពីអង្គការឃ្លាំមើលសិទ្ធិមនុស្សស្តីពីកម្ពុជា សូមមើល ៖**
http://www.hrw.org/asia/cambodia

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង ៖**

នៅក្នុងប្រទេសកម្ពុជា សូមទាក់ទង យូណា ពូយ៉ាល់ (ជាភាសាអង់គ្លេសនិងណេប៉ាល់)

ទូរស័ព្ទដៃលេខ +855-979945-557 និងតាមរយៈអ៊ីម៉ែល poudyaj@hrw.org
នៅក្នុងប្រទេសកម្ពុជា សូមទាក់ទង ចេម រ៉ូស (ជាភាសាអង់គ្លេស) ទូរស័ព្ទដៃលេខ
+855-977-044-169 និងតាមរយៈអ៊ីម៉ែល rossj@hrw.org
នៅទីក្រុងញូយ៉ក សូមទាក់ទង នីសា វ៉ារា (ជាភាសាអង់គ្លេស-អេស្បាញ) ៖ ទូរស័ព្ទដៃលេខ
+1-212-216-1858 ឬ +1-917-617-1041 ឬអ៊ីម៉ែល varian@hrw.org

**សាច់រឿងដែលបានជ្រើសរើសពីជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេដែលបានសម្ភាសន៍សម្រាប់របាយការណ៍នេះ ៖**

**ឈ្មោះពិតរបស់អ្នកផ្តល់បទសម្ភាសន៍ មិនបានប្រើទេ ដើម្បីការពារអត្តសញ្ញាណរបស់ពួកគេ។**

**សន ស្រីល័ក្ខ** ជាពលករធ្វើការតាមផ្ទះ បានពិពណ៌នាអំពីបទពិសោធន៍របស់នាងនៅឯមណ្ឌលហ្វឹកហ្វឺន ដូច្នេះថា ៖

> ពីរអាទិត្យ ក្រោយពីការចាប់ផ្តើមរស់នៅក្នុងមជ្ឈមណ្ឌល ខ្ញុំធ្លាក់ខ្លួនឈឺ។ ខ្ញុំហៅម្តាយខ្ញុំ និងសុំឲ្យគាត់យកលុយមកសងបំណុលគេ ដើម្បីឲ្យខ្ញុំ [អាច] ត្រឡប់ទៅផ្ទះវិញ។ ប៉ុន្តែក្រុមហ៊ុនបង្គាប់ឲ្យម្តាយខ្ញុំសងពួកគេ ៤៥០ ដុល្លារ។ យើងអត់មានលុយទេ។ តើយើងសងពួកគេយ៉ាងម៉េចទៅ?

**ចេន ចន្នី** ជាពលករធ្វើការតាមផ្ទះ ដែលបានចាប់ផ្តើមងើបធ្វើការងាររៀងរាល់ថ្ងៃ នៅម៉ោង ៥:០០ព្រឹក និងចូលទៅដេកបាន នៅម៉ោង ៣:០០ ព្រឹក មិនដែលមានឱកាសសម្រាកទេ។ នាងបានពិពណ៌នាអំពីបទពិសោធរបស់នាងនៅឯលំនៅដ្ឋានរបស់និយោជករបស់នាងក្នុងប្រទេសម៉ាឡេស៊ីដូច្នេះថា ៖

> ប្រសិនជាខ្ញុំបញ្ចប់ការងាររបស់ខ្ញុំលឿន ថៅកែខ្ញុំឲ្យខ្ញុំសម្អាតផ្ទះម្តងទៀត។ ប្រពន្ធថៅកែស្រែកដាក់ខ្ញុំ និងវាយខ្ញុំរាល់ថ្ងៃ។ គាត់ទាត់ [ខ្ញុំ] ទះខ្ញុំ ទាញសក់ខ្ញុំ និងវាយខ្លួនសព្វទីកន្លែងអស់ហើយ... ថៅកែប្រុសក៏យកដៃវាយខ្ញុំដែរ និងទាត់ខ្ញុំ។ ខ្ញុំអត់ដែលបានទទួលប្រាក់ខែទេ។

**ធី ធីប** អាយុ ១៦ ឆ្នាំ និងជាពលករធ្វើការតាមផ្ទះដែលត្រៀមចាកចេញ បានរំឭកពីបទពិសោធន៍របស់នាងអំឡុងពេលជ្រើសរើសនៅក្នុងប្រទេសកម្ពុជា ដូច្នេះថា ៖

ខ្ញុំបានប្រាប់មេខ្យល់ថា ខ្ញុំមិនទាន់គ្រប់អាយុទេ។ មេខ្យល់ប្រាប់ខ្ញុំថា មុខមាត់រាងវៅខ្ញុំមើលទៅចាស់ជាងអាយុ បើមិនទាន់ពេញវ័យ ក៏មិនជាអ្វីដែរ។ ខ្ញុំបានដាក់ពាក្យធ្វើការក្នុងប្រទេសម៉ាឡេស៊ី រកប្រាក់ជួយគ្រួសារ។ គ្រួសារខ្ញុំក្រណាស់។

**សុខ សែន** បានពិពណ៌នានូវអ្វីដែលបានកើតឡើង បន្ទាប់ពីភរិយារបស់គាត់រត់ចេញពីមណ្ឌលហ្វឹកហ្វឺនមួយ ដូច្នេះថា ៖

ប្រពន្ធខ្ញុំគាត់ត្រឡប់មកផ្ទះវិញ ប៉ុន្តែក្រុមហ៊ុនទាមទារឲ្យប្រពន្ធខ្ញុំសងលុយ ១,០០០ ដុល្លារ... ខ្ញុំព្យាយាមតាមរកប្រពន្ធខ្ញុំដែរ តែអត់ដឹងថាគាត់នៅឯណា... តំណាងក្រុមហ៊ុននិយាយថា បើប្រពន្ធខ្ញុំមិនត្រឡប់មកវិញទេ ពួកគេនឹងលក់ឡាយឡុងផ្ទះ និងដីនេះ។ បើលក់ឡាយឡុងហើយ បានលុយមិនគ្រប់ចំនួន ពួកគេនឹងចាប់ខ្ញុំដាក់គុក។

-----//-----